# បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

## ខិត្តបណ្ណ សម្រាប់កម្មករនិយោជិត

## ផ្នែកថែទាំសុខភាព

## តាវកាលិកថែទាំសុខភាពរួមមាន៖

**កញ្ចប់តាវកាលិក** **សេវាបង្ការសុខភាព**









### សម្រាប់ព័ត៌មានទាក់ទងនឹង ប.ស.ស

លេខទូរស័ព្ទព័ត៌មានបន្ទាន់: 1286 (24ម៉ោង/7ថ្ងៃ)

ទូរស័ព្ទលេខ: 023 882 623/ 023 88 24 34

Facebook ប.ស.ស : www.facebook.com/nssfpage

គេហទំព័រ: www.nssf.gov.kh

### អ្វីជារបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព?

សំដៅដល់ការផ្តល់ការព្យាបាល និងថែទាំវេជ្ជសាស្ត្រ សេវាបង្ការ និងប្រាក់បំណាច់ប្រចាំថ្ងៃដោយមានជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ និងសម្រាកមាតុភាព។

### លក្ខខណ្ឌដើម្បីទទួលបានតាវកាលិក

១.កំពុងបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកាក្នុង ប.ស.ស ផ្នែកថែទាំសុខភាព

២.បានចុះបញ្ជិកាក្នុង ប.ស.ស និង

៣.បានបង់ភាគទានចំនួន ០២ខែជាប់គ្នាឬ០៦ខែក្នុងកំឡុងពេល ១២ខែចុងក្រោយ គិតរហូតមកទល់ខែដែលមានបញ្ហាសុខភាពឬមាតុភាព។

### សេវាមិនរាប់បញ្ចូល

១-ការព្យាបាលដោយមិនគិតថ្លៃ ដែលមានចែងនៅក្នុងគោលនយោបាយសុខាភិបាលសាធារណៈ

២-ការថែទាំធ្មេញ (ការសំអាត ការប៉ះ និងការដាក់ធ្មេញ)

៣,ការព្យាបាល និងការវះកាត់ប្តូរភេទ

៤,ការផ្សាំ ឬប្តូរសរីរាង្គផ្សេងៗ

៥,សេវាបង្កកំណើតដោយសិប្បនិម្មិត

៦,ការព្យាបាលដោយខ្លួនឯង

៧,ការព្យាបាល ឬវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាងកាយ

៨,ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ

៩,ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន

១០,ការព្យាបាលអសមត្ថភាពផ្តល់កំណើត

១១,ការវះកាត់ដោយដាក់គ្រាប់ភ្នែកសប្បនិម្មិត

១២,ការវះកាត់បេះដូង និងសរសៃឈាមបេះដូង

១៣,ការលាងឈាម

១៤,ការព្យាបាលមហារីកដោយសារធាតុគីមី

*ការពិនិត្យសុខភាពទូទៅ

*បញ្ជាក់៖ ក្នុងករណីសង្គ្រោះបន្ទាន់ សេវាដូចបានចែងខាងលើត្រូវបានផ្តល់ជូន។*

### ការផ្តល់សេវាប្រភេទជំងឺរ៉ាំរ៉ៃ

ការផ្តល់សេវាពិគ្រោះជំងឺក្រៅ និងសម្រាកពេទ្យ ហើយប្រើប្រាស់តែឱសថសារវន្ត ដែលមាននៅក្នុង មូលដ្ឋានសុខាភិបាលសាធារណៈប៉ុណ្ណោះ។

ចំពោះឱសថក្រៅពីឱសថសារវន្តជាបន្ទុករបស់សមាជិក ប.ស.ស ផ្ទាល់។ ប្រភេទជំងឺរ៉ាំរ៉ៃទាំងនេះមានជាអាទិ៍៖

១-ជំងឺខ្សោយបេះដូង

២-ជំងឺសាច់ដុំបេះដូង

៣-ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ

៤-ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ

៥-ជំងឺតំរងនោមរ៉ាំរ៉ៃ

៦-ជំងឺក្រិនថ្លើម

៧-ជំងឺសរសៃឈាមក្រហមបេះដូង

៨-ជំងឺទឹកនោមផ្អែមប្រភេទទី១ និងទី២

៩-ជំងឺវិបត្តិចង្វាក់បេះដូង

១០-ជំងឺក្រិនសរីរាង្គ

១១-ជំងឺវិកលចរិត

១២-ជំងឺលុយពុស

១៣-ជំងឺលើសឈាម

១៤-ជំងឺតាឡាសេមី

### សេវាបង្ការសុខភាពរួមមាន៖

១-សេវាចាក់វ៉ាក់សាំងការពារជំងឺផ្តេសាយ

២-សេវាចាក់សេរ៉ូមប្រឆាំងជំងឺផ្តេសាយ

៣-សេវាចាក់សេរ៉ូមប្រឆាំងជំងឺតេតាណូស

៤-សេវាចាក់សេរ៉ូម ប្រឆាំង ពិសពស់

៥-សេវាពិនិត្យឈាមរកជំងឺពក ក មាន៖ TSH (Thyroid Stimulating Hormone) និងFree T3(Free Triiodothyronine) Free T4(Free Thyroxine)

៦-សេវាពិនិត្យឈាម កំណត់អបោធាតុមហារីក ក្រោយការព្យាបាលជំងឺមហារីកដោយវះកាត់ និង/ឬ ក្រោយការព្យាបាល ជំងឺមហារីកដោយចាក់គីមី និង/ឬក្រោយការព្យាបាល ជំងឺមហារីក ដោយបាញ់កាំរស្មីអ៊ិច មាន៖ CA15-3 (Cancer Antigen 15-3), CA19-9 (Cancer Antigen 19-9), Ca125 (Cancer Antigen 125), PSA (Prostate-Specific-Antigen), HCG (Beta-Human Chorionic Gonadotropin)

# តារាងលិក (អត្ថប្រយោជន៍) ថែទាំសុខភាពដែលកម្មករនិយោជិតទទួលបានមាន ការផ្តល់កញ្ចប់តារាងលិកសុខភាព និងសេវាបង្ការសុខភាពរួមមាន៖

## ក.កញ្ចប់តារាងលិកសុខភាព

### ក.១.សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

-ការព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ៖

សេវាព្យាបាលថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត សម្ភារបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល ឱសថតាមវេជ្ជបញ្ជា បន្ទប់(ធម្មតា) និងអាហារដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល។



-សេវាពិគ្រោះជំងឺក្រៅ៖សេវាព្យាបាលថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ រូប-ភាពវេជ្ជសាស្ត្រ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត បរិក្ខារសល្យសាស្ត្រ និងវេជ្ជសាស្ត្រផ្សេងៗ ដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល និងឱសថតាមវេជ្ជបញ្ជា។



-សេវាសង្គ្រោះបន្ទាន់ ជាអន្តរាគមន៍ទាំងឡាយណា ដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក ហើយអន្តរាគមន៍ទាំងនោះអាចត្រូវធ្វើឡើងភ្លាមក្នុងគោលបំណងសង្គ្រោះជីវិត ឬជួយការពារការបាត់បង់អវៈយវៈណាមួយនៃ សរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ។

-សេវាព្យាបាលដោយស្ពំ និងដោយចលនា





-សេវាសម្រាលកូន និងសេវាព្យាបាលថែទាំមុន និងក្រោយពេលសម្រាលកូន ។





-សេវាស្តារនីតិសម្បទា ផ្តល់ដោយ ប.ស.ស កម្មវិធីជាតិ អង្គភាព ឬ ស្ថាប័ន និងអង្គការទាក់ទងទៅនឹងការស្តារនីតិសម្បទាដទៃទៀត។





### ក.២-សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះ និងសេវាបញ្ជូនសព





### ក.៣-ប្រាក់បំណាច់ប្រចាំថ្ងៃ៖

១-មានជំងឺ ឬគ្រោះថ្នាក់ ជាយថាហេតុបណ្តាលឲ្យអាក់ខានការងារចាប់ពី ០៨ថ្ងៃឡើងទៅ និងដោយមានវេជ្ជបញ្ជាប្រាក់បំណាច់ប្រចាំថ្ងៃ ជាបន្ទុករបស់ ប.ស.ស។

២-សម្រាកមាតុភាព ត្រូវបានបង់ភាគទានយ៉ាងតិចចំនួន០៩ ខែជាប់គ្នា ដោយភ្ជាប់មកជាមួយនូវសេចក្តីចម្លងសំបុត្រកំណើតកូន។ ប.ស.ស ផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃចំនួន ៩០ថ្ងៃ។

*ប្រាក់បំណាច់ប្រចាំថ្ងៃនេះ ប.ស.ស ផ្តល់ជូនចំនួន ៧០%*
*នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ របស់កម្មករនិយោជិត។*

## ខ.សេវាបង្ការសុខភាព

សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ ការផ្តល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់ដទៃទៀត ដើម្បីការពារកុំឲ្យមានបញ្ហាសុខភាពមានជាអាទិ៍ ការស្រាវជ្រាវរកជំងឺ ការអប់រំសុខភាព និងកម្មវិធីចាក់ថ្នាំបង្ការ។ សេវាបង្ការ សុខភាពផ្តល់ដោយ ប.ស.ស កម្មវិធីជាតិ អង្គភាព ឬស្ថាប័ន និងអង្គការទាក់ទងទៅនឹងបញ្ហាសុខភាពដទៃទៀត។

*****ដើម្បីទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ដោយឥតគិតថ្លៃ កម្មករនិយោជិត**

ត្រូវភ្ជាប់មកជាមួយនូវបណ្ណសមាជិកភាព ប.ស.ស ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរអេឡិចត្រូនិច ឬឯកសារផ្សេងទៀតដែលអាចកំណត់អត្តសញ្ញាណសមាជិក ប.ស.ស បានហើយទៅប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលដែលបានចុះព្រមព្រៀងជាមួយ ប.ស.ស មានសំគាល់ដោយរូបសញ្ញា (LOGO) ប.ស.ស ចំនួន ១,២៨៤កន្លែង (គិតត្រឹមខែសីហា ឆ្នាំ២០១៧) ។